# ឈ្មោះទេពធីតាទាំង ៧

ឈ្មោះទេពធីតាដែលត្រូវវេនចុះមកអញ្ជើញក្បាលកបិលមហាព្រហ្ម
គឺទៅតាមថ្ងៃចូលឆ្នាំ បើ :

- ថ្ងៃអាទិត្យ ឈ្មោះទុង្សា សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ (ពណ៌ក្រហម) ភក្សាហារផ្លែឧទុម្ពរ អាវុធស្តាំចក្រ អាវុធឆ្វេងស័ង្ខ ពាហនៈគ្រុឌ ។
- ថ្ងៃចន្ទ ឈ្មោះគោរាគ សៀតផ្កាអង្គាបុស្ស គ្រឿងប្រដាប់មុក្តា (គជ់ខ្យង) ភក្សាហារប្រេង អាវុធស្តាំព្រះខ័ន ឆ្វេងឈើច្រត់ ពាហនៈខ្លា ។
- ថ្ងៃអង្គារ ឈ្មោះរាក្សសា សៀតផ្កាឈូក គ្រឿងប្រដាប់មោរា (កែវសម្បុរឆ្នូត) ភក្សាហារលោហិត អាវុធស្តាំត្រីសូល៍ ឆ្វេងធ្នូ ពាហនៈអស្សតរ (សេះ) ។
- ថ្ងៃពុធ ឈ្មោះមណ្ឌា សៀតផ្កាចម្ប៉ា គ្រឿងប្រដាប់ពិទូរ្យ ភក្សាហារទឹកដោះសប្បិ (ទឹកដោះថ្លា) អាវុធស្តាំម្ជុល ឆ្វេងឈើច្រត់ ពាហនៈលា ។
- ថ្ងៃព្រហស្បតិ៍ ឈ្មោះកិរិណី សៀតផ្កាមណ្ឌា គ្រឿងប្រដាប់មរកត ភក្សាហារសណ្តែក លូ អាវុធស្តាំកង្វេរ ឆ្វេងកាំភ្លើង ពាហនៈដំរី។
- ថ្ងៃសុក្រ ឈ្មោះកិមិរា សៀតផ្កាចង្កុលណី គ្រឿងប្រដាប់បុស្សរាគ័ម (ពណ៌លឿង) ភក្សាហារចេកណាំវ៉ា អាវុធស្តាំព្រះខ័ន ឆ្វេងពិណ ពាហនៈក្របី ។
- ថ្ងៃសៅរ៍ ឈ្មោះមហោទរា សៀតផ្កាត្រកៀត គ្រឿងប្រដាប់នីលរតន៍ ភក្សាហារសាច់ទ្រាយ ព្រះហស្តស្តាំកាន់កងចក្រ ព្រះហស្តឆ្វេងកាន់ត្រីសូល ពាហនៈសត្វក្ងោក ។

ទេពធិតាសុទ្ធតែសម្តែងកិរិយាផ្សេងៗដូចនេះ ៖

ពី ព្រលឹម ដល់ ថ្ងៃត្រង់ ជិះឈរលែងដៃ
ពី ថ្ងៃត្រង់ ដល់ ព្រលប់ អង្គុយពាក់ឆៀង
ពី ព្រលប់ ដល់ អាធ្រាត្រ ដេកបើកភ្នែក
ពី អាធ្រាត្រ ដល់ ភ្លឺ ដេកធ្មេចភ្នែក ។